# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៨ និងទិសដៅការងារឆ្នាំ២០០៩
# របស់ធនាគារជាតិនៃកម្ពុជា

**នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ១១-១២ ខែមិនា ឆ្នាំ២០០៩**

សូមគោរព :

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងឱកាសប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៨ និងទិសដៅការងារឆ្នាំ២០០៩ របស់ធនាគារជាតិនៃកម្ពុជា បន្ទាប់ពីថ្ងៃទិវានារីអន្តរជាតិ ៨ មិនា ។ ជារៀងរាល់ឆ្នាំ យើងតែងតែប្រារព្ធធ្វើសន្និបាតបូកសរុបលទ្ធផលការងារក្នុងបំណងដើម្បីផ្សព្វផ្សាយ និងអបអរសាទរពីលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាយើងសម្រេចបានកន្លងមកផង និងម្យ៉ាងទៀត ដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើង ទាំងនៅស្នាក់ការកណ្តាល និងនៅខេត្ត-ក្រុងបានជួបប្រាស្រ័យ និងរាប់អានគ្នាកាន់តែជិតស្និទ្ធ ដូចយើងរស់នៅក្រោមដំបូលគ្រួសារតែមួយជាមួយគ្នា ។

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាតំណាងនាយកដ្ឋាននានានៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើងនាពេលនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង ដែលបានរួមគ្នាកសាងសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជាកន្លងមក ពោលគឺ បានរួមចំណែកកសាងប្រព័ន្ធធនាគារយើងឱ្យមានការរីកចម្រើន មានសុវត្ថិភាព មានសុខភាពរឹងមាំ និងទទួលបានការជឿទុកចិត្តបន្ថែមទៀតពីសាធារណជនទូទៅ រាជរដ្ឋាភិបាល និងពីសហគមន៍អន្តរជាតិ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំអង្គសន្និបាតរបស់យើងថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ២០០៨

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាបានអនុវត្តក្នុងឆ្នាំ២០០៨ កន្លងមក

## ១. សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ២០០៨

នៅឆ្នាំ២០០៨កន្លងមកនេះ ពិភពលោកប្រឈមនឹងបញ្ហាធំៗបួនគឺ *ទី១*-ការឡើងថ្លៃខ្ពស់នៃប្រេងឥន្ធនៈ និងម្ហូបអាហារ *ទី២*-វិបត្តិឥណទាននិក្ខេប (Subprime Mortgage Loan Crisis) ដែលកើតមានឡើងនៅសហរដ្ឋអាមេរិក និងបានរីករាលដាលនៅអឺរ៉ុប និងទូទាំងពិភពលោក *ទី៣*-ការកើនឡើងខ្ពស់នៃសម្ពាធអតិផរណានៅលើពិភពលោក និង *ទី៤*-ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចពិភពលោក ដែលជាកត្តាដែលធ្វើឱ្យពិភពលោកប្រឈមមុខនឹងវិបត្តិធ្ងន់ធ្ងរ ។ នៅឆ្នាំ២០០៨ តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថាសេដ្ឋកិច្ចពិភពលោកមានអត្រាកំណើន ៣,៩% ទាបជាងឆ្នាំ២០០៧ត្រឹម ៥% ខណៈដែលសកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសមហាអំណាចឧស្សាហកម្ម និងប្រទេសនៃតំបន់អាស៊ី បានបង្ហាញនិន្នាការថយចុះ ។

ក្នុងឆ្នាំ២០០៨ កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក កើនក្នុងកម្រិត ១.៦% ធៀបនឹង ២% ឆ្នាំ២០០៧ សេដ្ឋកិច្ចនៅតំបន់អឺរ៉ុបកើនក្នុងកម្រិតត្រឹម ១,៣% ធៀបនឹង ២,៦% ឆ្នាំ២០០៧ ។ ប្រទេសចិនមានកំណើន ៩,៧% ធៀបនឹង ១១,៩% ឆ្នាំ២០០៧ និងកំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ាន+៣ វិញ មានកំណើន ៥,៩% ធៀបនឹង ៧,៦% នៅឆ្នាំ២០០៧ ដោយសារផលប៉ះពាល់ពីខាងក្រៅតំបន់ និងកត្តាផ្ទៃក្នុងខ្លួនឯង ។ ជារួម នៅឆ្នាំ២០០៨ សេដ្ឋកិច្ចពិភពលោកទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដែលតម្រូវឱ្យប្រទេសទាំងអស់យកចិត្តទុកដាក់ និងចាត់វិធានការជាបន្ទាន់ និងសមស្រប ។

ចំណែកឯសេដ្ឋកិច្ចកម្ពុជាវិញ មានអត្រាកំណើន ៧% នៅឆ្នាំ២០០៨ ទាបជាងការព្យាករពីដើមឆ្នាំត្រឹម ៧,៩% ។ ការធ្លាក់ចុះនៃល្បឿនកំណើននេះ បណ្តាលមកពីឥទ្ធិពលនៃវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិផង កត្តាចិត្តសាស្ត្រផង និងការកើនឡើងនៃសម្ពាធអតិផរណាក្នុងស្រុក បានធ្វើឱ្យប៉ះពាល់ដោយប្រយោលទៅលើវិស័យទេសចរណ៍ សំណង់ កម្មន្តសាល កសិកម្ម និងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

## ២. លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆ្នាំ២០០៨ កន្លងមក

ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព។

ជាលទ្ធផល ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាសំរេចបានសមិទ្ធផលសំខាន់ៗ ដូចតទៅ :

១)_**ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច** : ជារួម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាភាពល្អប្រសើរគួរឱ្យកត់សំគាល់ ។ តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក បានឡើងថ្លៃ ១% ប៉ុណ្ណោះ ក្នុងឆ្នាំ២០០៨ ។ ទោះបីកាលពីដើមឆ្នាំកន្លងមក សម្ពាធអតិផរណាបានកើនឡើងក្នុងកម្រិតពីរខ្ទង់ ប៉ុន្តែបានថយចុះមកវិញត្រឹម ១៣% នៅដំណាច់ឆ្នាំ បន្ទាប់ពីបានអនុវត្តវិធានការណ៍ជាកញ្ចប់របស់រាជរដ្ឋាភិបាល ប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពរួចមក ។ ការគ្រប់គ្រងទុនបំរុងអន្តរជាតិ យើងបានអនុវត្តដោយផ្អែកលើ មូលដ្ឋានប្រុងប្រយ័ត្ន និងសុវត្ថិភាពសាច់ប្រាក់ ដោយទុនបំរុងអន្តរជាតិបានកើនឡើង ២,២ពាន់លានដុល្លារអាមេរិក ដែលអាចធានាបាននូវការនាំចូលចំនួន ៣,៨ ខែ ។ នៅឆ្នាំ២០០៨កន្លងមក ដើម្បីរួមចំណែកទប់ទល់សម្ពាធ អតិផរណា ឆ្ពោះទៅពង្រឹងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានតម្លើងប្រាក់ បំរុងកាតព្វកិច្ចពី ៨% ទៅ ១៦% និងកំណត់ពិដានឥណទានរបស់ធនាគារពាណិជ្ជចំពោះវិស័យ អចលនទ្រព្យ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តយ៉ាងសកម្មនូវ កម្មវិធីកំណែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥ ហើយទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ ដូចខាងក្រោម :

២)_**ការពង្រឹងនិងអភិវឌ្ឍន៍ប្រព័ន្ធធនាគារ** ឱ្យមានការរីកចម្រើនទាំងវិសាលភាព និងទំហំសកម្មភាព ។ វិសាលភាព ក្នុងឆ្នាំ២០០៨ មានធនាគារពាណិជ្ជបើកថ្មីចំនួន ៥ និងធនាគារឯកទេសចំនួន ១ បានចូលមកវិនិយោគ ក្នុងទីផ្សារកម្ពុជា *ជាពិសេស* ការចូលមកវិនិយោគរបស់វិនិយោគិនមកពីអាមេរិក ជប៉ុន កូរ៉េ និងម៉ាឡេស៊ី ។ បច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជា មានធនាគារជាតិនៃកម្ពុជាជាអាជ្ញាធរអាណាព្យាបាល ធនាគារពាណិជ្ជចំនួន ២៤ ធនាគារឯកទេសចំនួន៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៨ អង្គការក្រៅរដ្ឋាភិបាលចុះបញ្ជីចំនួន ៦០ ។ ចំណែក ឯទំហំសកម្មភាពវិញ ប្រាក់បញ្ញើកើន ៦៥% ទាបជាងឆ្នាំមុនៗ ៧៤% និងឥណទានធនាគារពាណិជ្ជ ចំពោះវិស័យ ឯកជនកើន ៨៩% ធៀបនឹងឆ្នាំ២០០៧ កើន ៥១% ។ ឥណទានមិនដំណើរការ (NPL) បានថយចុះជាលំដាប់ រហូតដល់ ៣,៦% ធៀបនឹង ៥,៤% នៅឆ្នាំ២០០៧ ។ ប្រព័ន្ធធនាគារនៅកម្ពុជា ត្រូវគេចាត់ទុកថា បានដើរតួនាទី ជាស្នូលក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

៣)_**ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** (FIU) បន្ទាប់ពីច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មចូលជាធរមាន អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងកាល ពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

៤)_**វិស័យមីក្រូហិរញ្ញវត្ថុ** : ត្រូវបានមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសទទួលស្គាល់ថា **ជាវិស័យគន្លឹះក្នុងការ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា** ។ បច្ចុប្បន្ន វិស័យនេះ មានភាពរឹងមាំទាំងរចនាសម្ព័ន្ធ និងទាំងទំហំប្រតិបត្តិការរបស់ខ្លួនដល់ជនបទ ។ នៅឆ្នាំ២០០៨ មានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនជាង

៨៥២ ពាន់គ្រួសារ បានទទួលឥណទានចំនួន ១.១៦១ ពាន់លានរៀល កើនឡើងចំនួន ៨១% និងអតិថិជនបាន កើនឡើងចំនួន ៣៦% បើប្រៀបធៀបនឹងឆ្នាំ២០០៧ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិការឥណទាន បាន ទទួលប្រាក់បញ្ញើប្រមាណ ២៦ពាន់លានរៀល និងមានអ្នកផ្ញើប្រាក់ចំនួន ១៥៥ពាន់នាក់ ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យ ឃើញថា ប្រជាពលរដ្ឋកម្ពុជាមានការជឿទុកចិត្ត និងការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ ឥណទាន កាន់តែប្រសើរឡើង ។

**៥)_ការងារត្រួតពិនិត្យធនាគារ :** ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានពង្រឹង ការគ្រប់គ្រងប្រព័ន្ធធនាគារ និងបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យជាប់ជាប្រចាំ តាមរយៈការដាក់កម្មវិធីចុះទៅត្រួតពិនិត្យ ដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ និងបានជម្រុញឱ្យបណ្តាធនាគារពាណិជ្ជទាំងអស់ ពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងឱ្យធនាគារទាំងនោះធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ ខ្លួនជាសាធារណៈ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន មកលើប្រព័ន្ធធនាគារ ។

**៦)_ការពង្រឹងក្របខ័ណ្ឌច្បាប់ :** នៅឆ្នាំ២០០៨ យើងបានរៀបចំប្រកាសដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំង ការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ច្បាប់នេះ គឺជាមូលដ្ឋានគតិយុត្តិសំខាន់មួយសម្រាប់គ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបនូវរាល់ប្រតិបត្តិការ ឬបទល្មើស ដែលទាក់ទងនឹងប្រតិបត្តិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅកម្ពុជា ។ សេចក្តីព្រាងច្បាប់ស្តីពីភតិសន្យា ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័ត និងបញ្ជូនទៅរដ្ឋសភារួចហើយ ។ ច្បាប់នេះ គឺជាមូលដ្ឋានគតិយុត្តមួយសំរាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា និងសំរាប់កៀងគរ ប្រភពទុនរយៈពេលវែង ទៅពង្រីកគម្រោងវិនិយោគប្រកបដោយចីរភាព ។

**៧)_ការងារសវនកម្មផ្ទៃក្នុង :** ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារត្រួតពិនិត្យ ផ្ទៃក្នុងតាមរយៈការធ្វើសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ យើងបានដាក់ចេញនូវ ប្រកាសស្តីពីគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ប្រកាសស្តីពីក្រមសីលធម៌ សម្រាប់មន្ត្រី បុគ្គលិកអគ្គាធិការដ្ឋាន និងប្រកាសស្តីពីមុខងារភារកិច្ចរបស់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ។ នៅឆ្នាំ២០០៨ យើងក៏បាន ចុះធ្វើសវនកម្មនៅនាយកដ្ឋានប្តូរប្រាក់ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និងនាយកដ្ឋានគណនេយ្យ សាខា ធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ស្វាយរៀង កំពង់ធំ កំពង់ឆ្នាំង កោះកុង និងកំពត និងបន្តធ្វើសវនកម្ម តាមសាខាមួយចំនួនទៀត ។

**៨)_ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត_ក្រុង :**

ធនាគារជាតិនៃកម្ពុជា បានពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត-ក្រុង ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ តាមរយៈការបង្កើន ប្រសិទ្ធភាពគ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ ការបង្វែរសាច់ប្រាក់របស់រតនាគារជាតិ និងបើកប្រាក់បៀវត្សរ៍ជូន មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

**៩).ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិវិញ :** នៅឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងក្របខ័ណ្ឌមាត្រាទី IV និងជំនួយបច្ចេកទេស ។ ជាមួយ**មជ្ឈមណ្ឌល SEACEN** ធនាគារជាតិនៃកម្ពុជាបានសហប្រតិបត្តិការរៀបចំសិក្ខាសាលានៅខេត្តសៀមរាប និងបញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលានៅបរទេស ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៃការគ្រប់គ្រងនយោបាយរូបិយវត្ថុ និងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ។ យើងបាន ចូលរួមសន្និសីទថ្នាក់ទេសាភិបាល SEACEN លើកទី៤៣ នៅប្រទេសឥណ្ឌូនេស៊ី និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៦ នៅប្រទេសថៃ ។ ជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ធនាគារជាតិនៃកម្ពុជាបានទទួលរៀបចំសិក្ខាសាលាគំរូមួយ (Typologies Workshop) នៅខេត្តសៀមរាបក្នុងឆ្នាំ២០០៩នេះ ។

ចំពោះទំនាក់ទំនងទ្វេភាគីវិញ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ ធនាគារកណ្តាលលុចហ្សំបួរ ធនាគារកណ្តាលប៊ែលហ្ស៊ិក ធនាគារកណ្តាលអាល្លឺម៉ង់ និងបានចុះអនុស្សរណៈយោគយល់គ្នាជាមួយធនាគារកណ្តាលកូរ៉េ វៀតណាម និងឡាវ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនាគារកណ្តាល ការបណ្តុះបណ្តាលនិងផ្លាស់ប្តូរមន្ត្រីជំនាញនៃធនាគារកណ្តាលជាមិត្តទាំងនោះ ។

**លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងនេះ គឺជាលទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែង និងការចូលរួមនៃកម្លាំងសរុបរបស់មន្ត្រីបុគ្គលិកទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់មន្ត្រីយើងក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ ក្នុងអង្គសន្និបាតរបស់យើងរយៈពេលពីរថ្ងៃនេះ សូម លោក លោកស្រីទាំងអស់ ខិតខំត្រងត្រាប់ស្តាប់មន្ត្រីឧទ្ទេសនាមរបស់យើងនឹងផ្សព្វផ្សាយអំពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារឆ្នាំ២០០៩ សម្រាប់អនុវត្តឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម និងលោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**